ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

# ឥទ្ធិពលនៃប្រព័ន្ធចង្វាក់ចៀររង្វើលទៅលើទិន្នផលជ័រកៅស៊ូក្លូន PB217

## សេចក្តីផ្តើម

ការប្រមូលផលទឹកជ័រកៅស៊ូនៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិផ្សេងទៀតដែរ បានជួបនូវបញ្ហាប្រឈមមួយចំនួនដូចជា កង្វះកម្លាំងពលកម្មចៀរជ័រ និងតម្លៃពលកម្មឡើងថ្លៃជាដើម។ ដូច្នេះ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (វ.ស.ក.ក.) បានធ្វើការសិក្សាស្រាវជ្រាវលើសក្តានុពលទិន្នផលកៅស៊ូនៃប្រព័ន្ធចង្វាក់ចៀររង្វើល (d4, d5, d6) ដោយធ្វើការប្រៀបធៀបជាមួយប្រព័ន្ធចង្វាក់ចៀរដែលបានអនុវត្តស្ទើតែគ្រប់ចម្ការកៅស៊ូទាំងអស់នៅក្នុងប្រទេសកម្ពុជាគឺ d3។

## សម្ភារ និងវិធីសាស្ត្រស្រាវជ្រាវ

កៅស៊ូក្លូន PB 217 ត្រូវបានដាំនៅឆ្នាំ២០០៦ លើផ្ទៃដីចម្ការពិសោធន៍ទំហំ ៣,៤៦ហិកតា នៅស្ថានីយពិសោធន៍នៃ វ.ស.ក.ក. ស្ថិតក្នុងខេត្តត្បូងឃ្មុំ ហើយបានបើកមុខចៀរជ័រដំបូងនៅឆ្នាំ២០១៣។ ប្លង់ពិសោធន៍ត្រូវបានរៀបចំឡើងតាមប្លុកចាប់ឆ្នោតពេញលេញ (RCBD) ដោយមាន ៤បច្ច័យ និង៤សា។ ប្រព័ន្ធចៀរ គឺ S/2 d3 7d/7, S/2 d4 7d/7, S/2 d5 7d/7 និង S/2 d6 7d/7 (តារាងទី ១)។

តារាងទី១. បច្ច័យពិសោធន៍

| បច្ច័យ | ប្រវែងមុខចៀរ | ចង្វាក់ចៀរ | រំញោចកម្ម (ឆ្នាំចៀរ ១-៣) | រំញោចកម្ម (ឆ្នាំចៀរ ៤-៨) |
|---|---|---|---|---|
| T0 | S/2 | d3 7d/7 | ET 2.5% Pa1(1) 8/y | ET 2.5% Pa1(1) 10/y |
| T1 | S/2 | d4 7d/7 | ET 2.5% Pa1(1) 12/y | ET 2.5% Pa1(1) 14/y |
| T2 | S/2 | d5 7d/7 | ET 3.3% Pa1(1) 12/y | ET 3.3% Pa1(1) 15/y |
| T3 | S/2 | d6 7d/7 | ET 3.3% Pa1(1) 18/y | ET 3.3% Pa1(1) 20/y |

## លទ្ធផល

តារាងទី២. ទិន្នផលជ័រកៅស៊ូស្ងួតមធ្យមរយៈពេល៨ឆ្នាំនៃការចៀរជ័រ

| | S/2 d3 7d/7 + Stim | S/2 d4 7d/7 + Stim | S/2 d5 7d/7 + Stim | S/2 d6 7d/7 + Stim |
|---|---|---|---|---|
| nb tappings/year | 102 | 81 | 64 | 54 |
| % | 100% | 79% | 63% | 53% |
| g/t/tapping | 49.1 | 60.1 | 68.9 | 77.4 |
| % | 100% | 123% | 140% | 158% |
| g/t/year | 5006 | 4870 | 4407 | 4180 |
| % | 100% | 97% | 88% | 83% |
| kg/ha/year | 2002 | 1948 | 1763 | 1672 |
| % | 100% | 97% | 88% | 83% |
| kg/tapper/day | 24.5 | 30.1 | 34.4 | 38.7 |
| % | 100% | 123% | 140% | 158% |
| Area/tapper (ha) | 3.0 | 4.0 | 5.0 | 6.0 |
| % | 100% | 133% | 167% | 200% |

## សន្និដ្ឋាន

- ការកាត់បន្ថយចង្វាក់ចៀរនាំអោយផលិតភាពដីថយចុះតិចតួច ប៉ុន្តែនាំអោយផលិតភាពការងារចៀរជ័រមានការកើនឡើងខ្ពស់
- ក្នុងករណីកង្វះកម្លាំងពលកម្មចៀរជ័រ ការអនុវត្តប្រព័ន្ធចង្វាក់ចៀររង្វើលអាចជួយបង្កើនផ្ទៃដីចៀរជ័រសម្រាប់កម្មករម្នាក់ៗ។